ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ២ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I. ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

១៥-០១-១៩៩៦- អនុក្រឹត្យលេខ ០៣ អនក្រ ស្តីពីការផ្ទេរឥណទាន ៤៧

១៥-០១-១៩៩៦- អនុក្រឹត្យលេខ ០៤ អនក្រ ស្តីពីការបង្វែរឥណទាន ៤៨

០៩-០១-១៩៩៦- អនុក្រឹត្យលេខ ០៦ អនក្រ.តត ស្តីពីការតែងតាំង និងផ្លាស់ប្តូរមុខងារ នាយទាហាន ៥០

១០-០១-១៩៩៦- អនុក្រឹត្យលេខ ០៧ អនក្រ.តត តែងតាំងលោកស្រី **សុខ ឡេងបូរ៉ា** ជានាយិកាពិធីការ នៃខុទ្ទកាល័យ សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីទី ២ ៥២

១១-០១-១៩៩៦- អនុក្រឹត្យលេខ ០៨ អនក្រ.តត ស្តីពីការតែងតាំង ផ្លាស់ប្តូរមុខងារនាយទាហាន ៥៣

១១-០១-១៩៩៦-អនុក្រឹត្យលេខ ០៩ អនក្រ.តត ស្តីពីការផ្ទេរ និងតែងតាំងលោក **អ៊ុង សៅ** និងលោក **ឈិត សុខុម** ជាអភិបាលរងទី ២ ខេត្តតាកែវ ៥៤

១១-០១-១៩៩៦- អនុក្រឹត្យលេខ ១០ អនក្រ.តត ស្តីពីការផ្ទេរ និងតែងតាំងលោក **កែវ ហាន** និងលោក **ប៉ាសុជាតិវង្ស** ជាអភិបាលរងទី ២ ខេត្តកំពង់ធំ ៥៥

១២–០១–១៩៩៦– អនុក្រឹត្យលេខ ១១ អនក្រ.តត ស្តីពីការតែងតាំងលោក **ឡាង ចំនួ** ជាអគ្គនាយករងអគ្គនាយកដ្ឋានរដ្ឋបាល លោក **សក់ សេដ្ឋា** ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅក្រសួងមហាផ្ទៃ ៥៦

២ - សេចក្តីសំរេច

១២–០១–១៩៩៦– សេចក្តីសំរេច ០១ សសរ ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៧

៣ - សារាចរ

១៥–០១–១៩៩៦– សារាចរលេខ ០២ សរ. ស្តីពីការរៀបចំធ្វើគំរោងប្លង់គោល នៅតាមខេត្ត–ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា ៥៨

II - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

១០–០១–១៩៩៦ –ប្រកាសលេខ ០០៣ សហវ.ទរ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ និងលេខាធិការដ្ឋាន ដើម្បីអនុវត្តអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ៦១

១៥–០១–១៩៩៦– ប្រកាសលេខ ០០៤ សហវ.មប្រក ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ ៦៤

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

១១-០១-១៩៨៦- ប្រកាសលេខ ០៧ ផក.ប្រក អនុញ្ញាតអោយលោក **ម៊ុន ចាន់ធូ** ជនជាតិខ្មែរ បន្តដំណើរការសហគ្រាសកាត់ដេរសំលៀកបំពាក់ ៦៧

១២-០១-១៩៨៦- ប្រកាសលេខ ០៨ ផក.ប្រក អនុញ្ញាតអោយលោក **ជិន ឡើ** ជនជាតិខ្មែរ បន្តដំណើរការសិប្បកម្មផលិតទឹកត្រីសញ្ញា «ត្រីកំពតពីរ» ៦៨

១២-០១-១៩៨៦- ប្រកាសលេខ ០៩ ផក.ប្រក អនុញ្ញាតអោយលោក **សុខ ឆេងហួ** ជនជាតិខ្មែរបើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០ សេះ ៦៨

១២-០១-១៩៨៦- ប្រកាសលេខ ១០ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី **ម៉ែន សុគតី** ជនជាតិខ្មែរបន្តដំណើរការឡផលិតឥដ្ឋការ៉ូ ៦៩

១២-០១-១៩៨៦- ប្រកាសលេខ ១១ ផក.ប្រក អនុញ្ញាតអោយលោក **គីម ស្រ៊ី** ជនជាតិខ្មែរបន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ ៦៩

១២-០១-១៩៨៦- ប្រកាសលេខ ១២ ផក.ប្រក អនុញ្ញាតអោយលោក **គង់ ជាវរិទ្ធ** បន្តដំណើរការសិប្បកម្មកាត់ដេរសំលៀកបំពាក់ ៧០

១៥-០១-១៩៨៦- ប្រកាសលេខ ១៣ ផក.ប្រក អនុញ្ញាតអោយលោក **លី គីមពាច** ជនជាតិខ្មែរ បើកដំណើរការសហគ្រាសផលិតគ្រឿងសង្ហារឹម ៧០

១៥-០១-១៩៨៦- ប្រកាសលេខ ១៤ អនុញ្ញាតអោយលោក **សុខ ហុង** ជនជាតិខ្មែរបើកដំណើរការរោងម៉ាស៊ីន ផលិតទឹកកកដើម ៧១

៣ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

១៥-០១-១៩៨៦- ប្រកាសលេខ ០១៥/៨៦ ពម.ប្រក អនុញ្ញាតជូនលោក

ឧស

ស៊ីរី គិចសុវណ្ណ (SIRI KIT SUWAN) សញ្ជាតិថៃ
បើកក្រុមហ៊ុនផ្សព្វផ្សាយពាណិជ្ជកម្ម ៨

៤ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

១៣-០១-១៩៩៦- ប្រកាសលេខ ៤៣ អយក.ប្រក ស្ដីពីការប្ដូរឈ្មោះអនុវិទ្យាល័យ
ចរិយាវង្សទៅជាអនុវិទ្យាល័យ **ព្រះនរោត្ដម រណឫទ្ធិ** ស្ថិតនៅ
ស្រុកកំពត ខេត្តកំពត ៧

៥ - ទីស្ដីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

១១-០១-១៩៩៦ -ប្រកាសលេខ ០០៣ បទ.ប្រក អនុញ្ញាតអោយអង្គការមនុស្ស
លោកថ្មី ប្រើប្រាស់វិទ្យុទាក់ទងប្រភេទ VHF ចំនួន ០៥ គ្រឿង ៧៨

៦ - ទីស្ដីការក្រសួងធម្មការ និង សាសនា

សេចក្ដីប្រកាស

១០-០១-១៩៩៦ -សេចក្ដីប្រកាសលេខ ០៦/៩៦ កធស. លុបសេចក្ដីសំរេច
លេខ ២១៧/៩៥ កធស ចុះថ្ងៃទី ១២-១០-១៩៩៥ ៧៦

I - ទីស្ដីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ០៣ អនក្រ.

ស្ដីពីការផ្ទេរឥណទាន

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស /រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្ដីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជស/រកម/ ០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥

- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៤ អនក្រ.ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ស្តីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : ត្រូវបានផ្ទេរឥណទានចំនួន ២.៧០០លានរៀល(ពីរពាន់ប្រាំពីររយលានរៀល) ពីជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មកជាផលប្រយោជន៍ ជំពូក ៣០(អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) របស់ក្រសួងពាណិជ្ជកម្ម ក្នុងរង្វង់ថវិកាទូទៅ របស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ០៤ អនក្រ.

ស្តីពីការបង្វែរឥណទាន

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស /រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជស/រកម/ ០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៤ អនក្រ.ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ស្តីពីការកែតំរូវនៃច្បាប់ ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : ត្រូវបានបង្វែរឥណទានពីជំពូក ១០ (បៀវត្សនិងប្រាក់បំណាច់)ចំនួន ៦០លានរៀល (ហុកសិបលានរៀល) មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងជួសជុលតូច)ក្នុងវង្វង់ថវិការបស់ក្រសួងពាណិជ្ជកម្មសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ០៦ អនក្រ.តត

ស្ដីពីការតែងតាំង និងផ្លាស់ប្ដូរមុខងារ

នាយទាហាន

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើតក្រសួងការពារ ជាតិ និង អគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងមុខងារ និង ផ្ទេរភារកិច្ចនាយទាហាន ដែលមានរាយនាមដូចខាងក្រោម ÷

១_លោក វរសេនីយឯក **ថោង ប្រាសាន**		មេបញ្ជាការរងកងពលធំលេខ ៨ បច្ចុប្បន្នជាមេបញ្ជាការកងពលធំលេខ ៨
២_លោក វរសេនីយឯក **ម៉ូ ម៉ឺន**	:	នាយសេនាធិការរងយោធភូមិភាគទី បច្ចុប្បន្នជាមេបញ្ជាការរង យោធភូមិ, ទី ៤

៣_លោក វរសេនីយឯក **ឆាត់ ឈឿន**	មេបញ្ជាការរង កងពលធំលេខ ៤ បច្ចុប្បន្ន ជានាយសេនាធិការរង យោធភូមិភាគទី ៥
៤_លោក វរសេនិយឯក **ខឹម ឃោន**	មេបញ្ជាការរង កងពលធំលេខ ២ បច្ចុប្បន្នជានាយសេនាធិការរង យោធភូមិភាគ ៤
៥_លោក វរសេនិយឯក **គាត ប៊ុនហុង**	នាយសេនាធិការកងពលធំលេខ ១៤ បច្ចុប្បន្នជា នាយរងការិយាល័យ អភិវឌ្ឍន៍ អគ្គសេនាធិការ
៦_លោក វរសេនិយឯក **សាន សន**	មេបញ្ជាការវរសេនាធំលេខ ១២ បច្ចុប្បន្នជាមេបញ្ជាការរងកងពល ធំលេខ ៤
៧_លោក វរសេនិយឯក **គួក សឡៀម**	នាយសេនាធិការ កងពលធំលេខ ៧ បច្ចុប្បន្នជា នាយសេនាធិការរងយោធ ភូមិភាគទី ១

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនា ធិការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និង អស់លោក មានឈ្មោះខាង លើត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ០៧ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រី រាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : តែងតាំងលោកស្រី **សុខ ឡេងបូរ៉ា** ជានាយិកាពិធីការ នៃខុទ្ទកាល័យសម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីទី ២ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ០៨ អនក្រ.តត

ស្តីពីការតែងតាំងផ្លាស់ប្តូរមុខងារនាយទាហាន

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ពិនិត្យឃើញសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : តែងតាំងលោក **ស៊ូ ស៊ុម** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រីទី ២ ទទួលបន្ទុកការងារស្រាវជ្រាវឯកសារនិងពត៌មាន មានឋានន្តរសក្តិ ជាវរសេនិយឯក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ០៩ អនក្រ.តត

ស្តីពីការផ្ទេរ និង តែងតាំងមន្ត្រី រាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ. ចុះថ្ងៃទី ២០ ខែ ធ្នូ ១៩៩៣ ស្តីពីការតែងតាំងអភិបាលរងខេត្ត–ក្រុង
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានផ្ទេរលោក **អ៊ុង តៅ** ពីអភិបាលរងទី ២ ខេត្តតាកែវ អោយមកបំរើការងារនៅទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ២ : តែងតាំងលោក **ឈិត សុខុន** ជាអភិបាលរងទី ២ ខេត្តតាកែវ ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការបណ្តាក្រសួងពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១០ អនក្រ.តត

ស្តីពីការផ្ទេរ និង តែងតាំងមន្ត្រី រាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.ចុះថ្ងៃទី ២០ ខែ ធ្នូ ១៩៩៣ ស្តីពីការតែងតាំងអភិបាលរងខេត្ត_ក្រុង
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានផ្ទេរលោក **កែវ ហាន** ពីអភិបាលរងទី ២ ខេត្តកំពង់ធំ អោយមកបំរើការងារនៅទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ២ : តែងតាំងលោក **ម៉ា សុជាតិវង្ស** ជាអភិបាលរងទី ២ ខេត្តកំពង់ធំ ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការបណ្តាក្រសួងពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១១ អនក្រ.តត

ស្ដីពីការផ្ទេរ និង តែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងលោក **ប្រាជ្ញ ច័ន្ទ** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ និង លោក **សក់ សេដ្ឋា** ជាប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីនៃ ក្រសួងរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធជាមួយ និងលោក **ប្រាជ្ញ ច័ន្ទ** និងលោក **សក់ សេដ្ឋា** ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២ - សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៦

សេចក្តីប្រកាសលេខ ០១ សសរ

ស្តីពីការជូនបំណ្ណស្លាបនាជាតិ

* * *

សហរដ្ឋមន្ត្រីទទួលទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

ប្រការ ១ : ត្រូវបានប្រគល់ប័ណ្ណស្ថាបនាជាតិ ជូនចំពោះសម្បុរសជនជាសមូហភាព និងជាបុគ្គលដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគធនធានចូលរួមជួយកសាងសាលាបឋមសិក្សាមោងក្នុងស្រុក មោងឫស្សី ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ ÷

១–គណៈកម្មការសមាគមវត្តខេមរារាម នៅក្រុងម៉ូដែស្តូ សហរដ្ឋអាមេរិកជួយឧបត្ថម្ភប្រាក់ ៥០០ ដុល្លារអាមេរិក ។

២–គណៈកម្មការសមាគមមាតាបិតាសិស្ស សាលាបឋមសិក្សាមោងជួយឧបត្ថម្ភប្រាក់ ៥០០ ដុល្លារអាមេរិក ។

៣–លោក **ឈឹម សេងលី** នៅសហរដ្ឋអាមេរិក ជួយឧបត្ថម្ភប្រាក់ ៨៦០ ដុល្លារអាមេរិក

៤–លោក **ឌុច ឡើន** នៅសហរដ្ឋអាមេរិក ជួយឧបត្ថម្ភប្រាក់ ៨១០ ដុល្លារអាមេរិក

៥–លោក **ស៊ូ សុផល** នៅសហរដ្ឋអាមេរិក ជួយឧបត្ថម្ភប្រាក់ ៦៦០ ដុល្លារអាមេរិក

ប្រការ ២ : នាយកដ្ឋានប្រឡងប្រណាំង និងគ្រឿងឥស្សរិយយស នាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋានសរុប ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ អោយទទួលបានលទ្ធផលល្អ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

សុខ អាន   វ៉េងសិរីវុឌ្ឍ

* * *

៣ - សារាចរ

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦

សារាចរណែនាំលេខ ០២ សរ

ស្តីពីការរៀបចំរុះរើសំណង់ខុសប្លង់គ.រ.ជ នៅតាម

ខេត្ត–ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា

* * *

ចាប់តាំងពីរាជរដ្ឋាភិបាល ត្រូវបានបង្កើតឡើងរហូតមកដល់បច្ចុប្បន្ន វិស័យសេដ្ឋកិច្ចសង្គមមានការរីកចំរើនលូតលាស់គួរអោយមោទនភាព ។ ដោយឡែកការស្តារ និងការកសាងលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ និង សំណង់ក៏កំពុងមានសន្ទុះឈានទៅមុខយ៉ាងខ្លាំងក្លា ។ ប៉ុន្តែរាជរដ្ឋាភិបាលក៏បានសង្កេតឃើញថា ការកសាងហេដ្ឋានរចនាសម្ព័ន្ធថ្មី ការស្ថាបនារោងចក្រ សណ្ឋាគារ ភោជនីយដ្ឋាន ការស្ថាបនា ទីផ្សារ ការធ្វើសួនច្បារ ឧទ្យានសាធារណៈ តំបន់អភិវឌ្ឍន៍មជ្ឈមណ្ឌលទេសចរណ៍ តំបន់លំហែរកំសាន្ត ជាពិសេសលំនៅដ្ឋាន ហាងលក់ដូរទំនិញរបស់ប្រជារាស្ត្រ បានបង្កឡើងនូវភាពមិនសមស្របតាមបច្ចេកទេសនៃការរៀបចំទឹកដី នគរូបនីយកម្ម

និងសំណង់ ហើយសំណង់ភាគច្រើនចាស់ និងកំពុងតែ [illegible] ទៀតដោយអនាធិបតេយ្យធ្វើអោយខូចសោភ័ណភាពដល់ប្រជុំជន ទីរួមស្រុក ទីរួមខេត្ត និងទីក្រុង ។

ដើម្បីដោះស្រាយបញ្ហានេះ ដែលមានលក្ខណៈចាំបាច់ និងបន្ទាន់ចំពោះអនាគតរបស់ជាតិមាតុភូមិ អង្គរដ៏ឧត្តមនៃយើង រាជរដ្ឋាភិបាល សូមធ្វើការណែនាំចំពោះក្រសួង ស្ថាប័ន និងក្រុមខេត្ត–ក្រុង អោយអនុវត្តនូវវិធានការសំខាន់ៗ ដូចខាងក្រោម ៖

អនុលោមតាមច្បាប់ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ នៅជំពូកទី ២ មាត្រា ៥ ដែលបានចែងថា «គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ឬ អនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត–ក្រុង នីមួយៗ ត្រូវគូសប្លង់គោល ដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍន៍ នៃធានីភ្នំពេញ ខេត្ត–ក្រុងរបស់ខ្លួន ។ ប្លង់គោលនេះ ត្រូវមានការយល់ព្រមពី គណៈកម្មាធិការជាតិ រៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ និង កំណត់ដោយអនុក្រឹត្យ ។

ដើម្បីការពារនូវបេតិកភ័ណ្ឌ ការពារបរិស្ថាន និងដើម្បីធានាអភិវឌ្ឍន៍សេដ្ឋកិច្ច ចំពោះតំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់ គណៈកម្មាធិការជាតិ រៀបចំទឹកដីនគរូប–នីយកម្ម និង សំណង់ មានការរៀបចំប្លង់គោល សំរាប់តំបន់ ពិសេសនោះ ដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត »។

១–ដើម្បីប្រតិបត្តិច្បាប់ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃ ទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៤ អោយមានប្រសិទ្ធភាព រាជរដ្ឋាភិបាលសូមប្រគល់ភារកិច្ច ជូនក្រសួងមហាផ្ទៃ ណែនាំដល់សាលាក្រុងភ្នំពេញ និងសាលាខេត្ត–ក្រុងទូទាំងព្រះរាជាណាចក្រ កម្ពុជាត្រូវសហការជំរុញផ្នែកជំនាញ នៃគណៈកម្មាធិការរៀបចំទឹកដីនគរូបនីយ៍កម្ម និងសំណង់ រាជធានីភ្នំពេញ និងអនុគណៈកម្មាធិការរៀបចំ ទឹកដីនគរូបនីយកម្មនិងសំណង់ខេត្ត–ក្រុង អោយដំណើរការជាបន្ទាន់ នូវការគូសប្លង់គោល ដើម្បីធ្វើការរៀបចំនិងអភិវឌ្ឍន៍នៃរាជធានី ខេត្ត–ក្រុងរបស់ខ្លួន ដែលក្នុងនោះ ត្រូវកំណត់អំពីហេដ្ឋារចនាសម្ព័ន្ធបណ្តាញផ្លូវគមនាគមន៍ ទីតាំងទីផ្សារ តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់សណ្ឋាគារមណ្ឌលទេសចរណ៍ តំបន់កំពង់ផែ ចំណតរថយន្ត ចំណតរថភ្លើង ចំណតអាកាសយានដ្ឋានតំបន់សាលារៀនចំណេះ ទូទៅសាលារៀនបច្ចេកទេសទីវត្តអារ៉ាម តំបន់រដ្ឋបាលស៊ីវិលតំបន់នគរបាល តំបន់យោធា តំបន់ការពារបរិស្ថាន តំបន់សួនច្បារ ឧទ្យានសាធារណៈ កន្លែងចាក់សំរាមអាងស្តុកទឹកសំអុយ បណ្តាញលូបង្ហូរទឹក ការរៀបចំខ្សែបណ្តាញអគ្គិសនី ដីត្រៀមបំរុងអភិវឌ្ឍន៍

ព្រៃត្រៀមបម្រុង ជំរកសត្វព្រៃ បឹងបួរសាធារណៈ ទន្លេ ព្រែក សមុទ្រ កោះ ដីលំនៅដ្ឋានដីធ្វើស្រែចំការច្បារ ដំណាំផ្សេងៗ ។ល។

២-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងទេសចរណ៍ រួមជាមួយក្រសួងគ្រប់គ្រងបរិស្ថានត្រូវធ្វើការណែនាំជា បន្ទាន់ដល់មន្ទីរក្រោមឱវាទរបស់ខ្លួននៅគ្រប់ខេត្ត-ក្រុង អោយធ្វើការសិក្សា អំពីមុខជំនាញក្នុងការកំណត់ តំបន់ដីធ្លីសំរាប់ដំណាំកសិកម្ម ដំណាំកសិ-ឧស្សាហកម្ម និងដំណាំយុទ្ធសាស្ត្រផ្សេងៗ កំណត់តំបន់ដី សម្បទាន កំណត់តំបន់ព្រៃសម្បទាន តំបន់រោងចក្រឧស្សាហកម្ម មណ្ឌលទេសចរណ៍ ព្រៃឧទ្យានជាតិ ជំរកសត្វព្រៃ កសាងហេដ្ឋារចនាសម្ព័ន្ធ ។ល។ ដើម្បីរួមបញ្ចូលនៅក្នុងគំរោងប្លង់គោលតាមខេត្ត-ក្រុង នីមួយៗ សំដៅឈានទៅរៀបចំធ្វើប្លង់គោលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាមូលដ្ឋានជូន គណៈរដ្ឋមន្ត្រី ក្នុងការសំរេចកំណត់ដីធ្លី និងតំបន់ផ្សេងៗ សំរាប់ប្រគល់អោយក្រុមហ៊ុននានាធ្វើវិនិយោគ បំរើអោយការអភិវឌ្ឍន៍ប្រទេសជាតិ ធានាបាននិរន្តរ៍ភាពតទៅអនាគត និងធានាបានកិច្ចការពារបរិស្ថានទៀតផង ។

៣-គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ត្រូវធ្វើការណែនាំអំពីការងារ បច្ចេកទេសជំនាញលើការងាររៀបចំទឹកដី ការងារនគរូបនីយកម្ម និងការងារសំណង់ ទៅដល់គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ និងអនុគណៈ-កម្មាធិការរៀបចំ ទឹកដីនគរូបនីយកម្ម និង សំណង់ខេត្ត-ក្រុង អោយធ្វើជាសេនាធិការជូនអភិបាលខេត្ត-ក្រុង ក្នុងការរៀបចំធ្វើគំរោងប្លង់គោល ដើម្បីធ្វើការរៀបចំ និង អភិវឌ្ឍន៍ក្នុងក្របខ័ណ្ឌរង្វង់ដែនដីដែល ខេត្ត-ក្រុងនីមួយៗ គ្រប់គ្រង ។

ទទួលបានសារាចរនេះ ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងទេសចរណ៍ ក្រសួងគ្រប់គ្រង បរិស្ថាន ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់សាលាខេត្ត-ក្រុង ត្រូវចាត់ចែងផ្សព្វផ្សាយ និងទទួលអនុវត្ត អោយបានលទ្ធផលល្អប្រសើរ រួចស្នើរប្លង់គោលនេះ ចំនួន ៤ ច្បាប់ មកសុំការឯកភាព ពីក្រសួងមហាផ្ទៃជាមុន រួចទើបបញ្ជូនទៅគណៈកម្មាធិការជាតិរៀបចំទឹកដី

នគូរូបនីយកម្ម និងសំណង់ពិនិត្យ និង សុំការសំរេចពីរាជរដ្ឋាភិបាលអោយបានមុនដំណាច់ខែ កក្កដា ឆ្នាំ ១៩៩៦ ជាកំហិត ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្តលេខា និងត្រា **ហត្ថលេខា និង ត្រា**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

II - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០០៣ សហវ.ឥរ

ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការឯកជននាវូបនីយកម្ម

សហគ្រាសសាធារណៈ និងលេខាធិការដ្ឋាន

ដើម្បីអនុវត្តអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤,៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១១ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តី ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទ នៃ ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញតំរូវការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : តែងតាំង :

១-ឯកឧត្តម **ឆាយ ថន**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	ប្រធាន
២-លោកជំទាវ **ស៊ិន សេរី**	អគ្គលេខាធិការរង នៃរាជរដ្ឋាភិបាល	សមាជិក
៣-លោក **ខួន នៅ**	ប្រធាននាយកដ្ឋានផែនការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
៤-លោក **គីម ឡឿន**	ប្រធាននាយកដ្ឋានគណនេយ្យ ក្រសួងពាណិជ្ជកម្ម	សមាជិក
៥-លោក **ជា សុខ**	តំណាងធនាគារជាតិ នៃកម្ពុជា	សមាជិក
៦-លោក **សេង វ៉ុន**	ក្រុមប្រឹក្សាអ្នកច្បាប់	សមាជិក
៧-លោក **ហួយ សិទ្ធិគុណណ**	អនុប្រធាននាយកដ្ឋានក្រសួងផែនការ	សមាជិក
៨-លោក **អ៊ឹម ឆៃ**	អនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	សមាជិក
៩-លោក **ហួត ចាន់ធី**	អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ ក្រសួង សង្គមកិច្ចការងារ និងអតីតយុទ្ធជន	សមាជិក

១០–លោក **សុក ស៊ីវេន** មន្ត្រីការិយាល័យគណនេយ្យហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១១–លោក **ឃួត ឫទ្ធី** តំណាងក្រសួងយុត្តិធម៌ សមាជិក

១២–លោក **ការ៉ង លាងខំណា** អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាលេខាធិការនិងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការឯកជនភាវូបនីយកម្ម

១៣–លោក **ជូ ទិដិត្ត** មន្ត្រីខុទ្ទកាល័យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិកលេខាធិការដ្ឋាន

១៤–លោក **ឡាំ សុផល** មន្ត្រីនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិកលេខាធិការដ្ឋាន

១៥–លោក **នួន សំបូរ** មន្ត្រីនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសមាជិកលេខាធិការដ្ឋាន

ប្រការ ២ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធព្រមទាំងសាមីខ្លួន ក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០០៤ សហវ.មប្រក

ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : បទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ ដែលមានចែងក្នុងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ត្រូវចាប់ផ្តើមអនុវត្តចាប់តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៦ ចំពោះក្រសួងនានា ដែលជាអាណាប័កដើមខ្សែទាំងអស់ និងរតនាគារជាតិព្រមទាំង គណនេយ្យសាធារណៈ ដែលមានទីតាំងនៅរាជធានីភ្នំពេញ ដើម្បីអនុវត្តកិច្ចប្រតិបត្តិការ ចំណូល ចំណាយ ថវិការដ្ឋ ។ ការអនុវត្តដោយអាណាប័កតាមការប្រទានសិទ្ធិ និង គណនេយ្យករសាធារណៈនៅតាមខេត្តក្រុង នឹងត្រូវមានការកំណត់សំរេចជាក្រោយ ។

ប្រការ ២ : ចំពោះចំណូលពន្ធអាករ និងចំណូលផ្សេងៗ មានលក្ខណៈប្រហាក់ប្រហែលផលិតទ្រព្យរដ្ឋពិន័យ និងទណ្ឌវាទ ពិន័យជាប្រាក់កាស ត្រូវបានជំរះបញ្ជីផ្ទៀងផ្ទាត់មុននឹងធ្វើការប្រមូល ហើយត្រូវប្រមូលដោយដីកាចំណូល ។ ចំណូលថវិកាផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទបញ្ញាជាធរមាន ឬដោយការសំរេចរបស់តុលាការ ឬដោយអនុសញ្ញាផ្សេងៗទៀត ត្រូវជំរះបញ្ជី និងធ្វើការ ប្រមូលក្នុងល័ក្ខខ័ណ្ឌបញ្ញត្តិដោយលាយ ល័ក្ខអក្សរ ចំពោះចំណូលនិមួយៗនោះ ។

ប្រការ ៣ : ពិន័យរបស់នគរបាលពីបទល្មើសចរាចរ ត្រូវបានប្រមូលដោយស្នងការនគរបាល ដែលត្រូវ បង្កើតជារដ្ឋទេយ្យចំណូលដោយប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ភ្នាក់ងារនគរបាលត្រូវធ្វើកំណត់ហេតុផ្តល់ទៅអ្នកប្រព្រឹត្ត បទល្មើស ព្រមទាំងអញ្ជើញគេអោយ ទៅស្នងការនគរបាល ដើម្បីបង់ប្រាក់ពិន័យ ។

ប្រការ ៤ : គណនេយ្យកររដ្ឋបាល ហិរញ្ញវត្ថុ នាយកដ្ឋានពន្ធដារ និងទីចាត់ការគយ និងរដ្ឋាករ និងរដ្ឋទេយ្យករចំណូល ត្រូវបង់ចំណូលដែលខ្លួនបានទទួលទៅ អោយគណនេយ្យ ករមុខការ យ៉ាងតិចណាស់ក្នុងមួយខែម្តង រៀងរាល់ថ្ងៃទី ២៥ នៃខែនីមួយៗ និងថ្ងៃទី ៣១ ខែធ្នូ និងរាល់ពេលវេលាដែលគណនេយ្យករ មានប្រាក់ ក្នុងបេឡាលើសកំរិត នៃចំនួនប្រាក់ដែល បាន កំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ៥ : មុននឹងគណនេយ្យករធ្វើការបើកផ្តល់ ចំណាយរបស់រដ្ឋ ត្រូវបានធ្វើកិច្ចសន្យាជំរះ បញ្ជី និង ធ្វើអាណាប័ណ្ណដោយអាណាប័ក ។ នីតិវិធីនៃកិច្ចសន្យា ជំរះបញ្ជី និង អាណាប័ណ្ណ នឹងត្រូវ បញ្ជាក់ដោយសារាចរណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ៦ : ដើម្បីត្រួតពិនិត្យដំបូងរាល់ការចំណាយ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើង ហើយការបង្កើតនេះ ត្រូវអនុវត្តទៅតាមនិតិវិធី ដែលត្រូវបានកំណត់ដោយអនុក្រឹត្យ លេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ។ កិច្ចប្រតិបត្តិការនេះ ត្រូវធ្វើឡើងតាមរយៈ ប្រកាស និងការណែនាំដោយឡែក ។

ប្រការ ៧ : ការចំណាយណា ដែលមានទឹកប្រាក់ច្រើនជាងការកំណត់ ត្រូវអនុវត្តទៅតាម បែបបទ ដែលបានចែងក្នុង ប្រកាសលេខ ៣១៩៩ សហវ.ម ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការចំណាយធ្វើឡើងដោយ អាបណាសញ្ញាទាំងឡាយ ក្រោមរូបភាពដេញថ្លៃ ហើយត្រូវ សហការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានលទ្ធកម្ម សាធារណៈ ដែលការរៀបចំ និងដំណើរការ ត្រូវបានកំណត់ ដោយអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ។

ប្រការ ៨ : រាល់ការចំណាយរបស់រដ្ឋ ត្រូវធ្វើការបើកផ្តល់ដោយផ្ទាល់ពីរតនាគារជាតិ ឬរតនាគារ ខេត្ត ក្រុងក្រោយពីសេវាកម្មបានធ្វើហើយ ។ រាល់ការបើកផ្តល់ ដែលមានចំនួនទឹក

ប្រាក់លើសពី ២.៥០០.០០០ រៀលឡើងទៅ អាចធ្វើការទូទាត់តាមរយៈធនាគាររដ្ឋទេយ្យបុរេប្រទាន ។

ប្រការ ៩ : ការលើកលែងនូវគោលការណ៍ ដែលបានរៀបរាប់ក្នុងប្រការមុន អាចអនុវត្តបានចំពោះប្រភេទចំណាយមួយចំនួន និងចំណាយសំភារៈ ព្រមទាំងការថែទាំដែលមានទឹកប្រាក់ទាបជាង ៥០០.០០០ រៀល ហើយអាចប្រព្រឹត្តទៅតាមរដ្ឋទេយ្យបុរេប្រទាន ។ ដោយឡែកការ ចំណាយលើបៀវត្ស ចំណាយលើអគ្គិសនី ទឹក និង ពលិពិកាត្រូវធ្វើឡើងតាមរយៈភ្នាក់ងារ បើកផ្តល់ ។ ការរៀបចំ និងការប្រព្រឹត្តិទៅនៃរដ្ឋទេយ្យ ព្រមទាំងភ្នាក់ងារបើកផ្តល់ ត្រូវបានកំណត់រួមដោយរដ្ឋមន្ត្រីក្រសួងសាមី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវមានសារាចរណែនាំអោយអនុវត្តផង ។

ប្រការ ១០ : គណនេយ្យរបស់រដ្ឋ ត្រូវប្រកាន់យកនូវគណនេយ្យទ្វេភាគ និងជារូបិយវត្ថុជាតិតាមប្លង់គណនេយ្យទូទៅនៃកម្ពុជាជាធរមាន ។ អាណាប័កអាចកាន់គណនេយ្យរដ្ឋបាលសាមញ្ញ ។ រូបិយប័ណ្ណបរទេស ដែលបានទទួលជាចំណូលត្រូវបង់ទៅធនាគារជាតិជាបន្ទាន់ហើយ ធនាគារជាតិនៃកម្ពុជា នឹងប្តូរជារូបិយវត្ថុជាតិ មុននឹងបង្វែរទឹកប្រាក់នេះចូលទៅក្នុងគណនី រតនាគារជាតិ ឬរតនាគារខេត្ត ក្រុង ។ ចំពោះការចំណាយជារូបិយប័ណ្ណវិញ ធនាគារជាតិ នៃ កម្ពុជាត្រូវធានានូវកិច្ចប្រតិបត្តិប្តូរនេះ ។

ប្រការ ១១ : សេចក្តីសំរេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ១២: ក្នុងពេលអនុវត្តប្រកាសនេះ បើប្រសិនណាជាមានជួបការលំបាក ដោយប្រការណាមួយនោះ សូមអញ្ជើញមកទាក់ទងផ្ទាល់ ឬតាមលិខិតស្នាមផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ១៣: មន្ទីរ នាយកដ្ឋានពន្ធដារ នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញវត្ថុ រតនាគារជាតិ នាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធ ក្រោមឱវាទក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស់ មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៦ នេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

ប្រកាសលេខ :០៧ ឧក.ប្រក

* * *

ប្រការ១ : អនុញ្ញាតអោយលោក ម៉ិត ចាន់ឆ្ន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០២៧៥៤៦ ភ.ព ចុះថ្ងៃទី ០៩ - ០១ - ៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៨៥ អឺ០ ផ្លូវម៉ៅសេទុង សង្កាត់បឹងកេងកងទី៣ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរ ការសហគ្រាសកាត់ដេរសំលៀកបំពាក់ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៨៦

ប្រកាសលេខ :០៨ ជក.ប្រក

* * *

ប្រការ១ : អនុញ្ញាតអោយលោក **ជិន ទ្រី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៦០១៨៧ ភ.ព ចុះថ្ងៃទី ១១ - ១០ - ៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិត្បូង ឃុំព្រែកព្នៅ ស្រុក ពញាឮ ខេត្តកណ្តាល បន្តដំណើរការសិប្បកម្ម ផលិតទឹកត្រី សញ្ញា « ត្រីកំពតពីរ » នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ២ : លោក ជិន ទ្រី ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលទឹកត្រី សញ្ញា « ត្រីកំពតពីរ » ស្របតាមគំរូ និងផ្លាកសញ្ញា ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៨៦

ប្រកាស លេខ :០៩ ជក.ប្រក

* * *

ប្រការ១ : អនុញ្ញាតអោយលោក **សុខ ឆេងហួ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៦២៣៨៨ ក.ណ ចុះថ្ងៃទី ២៥ - ១២ - ៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិស៊ីធរ ឃុំស៊ីធរ ស្រុក ខ្សាច់កណ្តាល ខេត្តកណ្តាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ២ : លោក **សុខ ឆេងហួ** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ។

ប្រការ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១០ ឧក. ប្រក

ប្រការ១ : អនុញ្ញាតអោយអ្នកស្រី **ម៉ែន សុភគី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៤៤០៦០ ភ.ព ចុះថ្ងៃទី ២៦ - ៣ - ៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៥៧ ផ្លូវលេខ ១៥៥ សង្កាត់ទួលទំពូងទី១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការ ឡផលិតឥដ្ឋការ៉ូ « ផ្សារដើមថ្កូវ » នៅក្នុងទីតាំងដីឡូត៍ថ្មី ផ្លូវលេខ ៤៨៨ ក្រុមទី ១៤ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មាន សំណងឡើយ ។

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៦

ប្រកាសលេខ :១១ ឧក. ប្រក

* * *

ប្រការ១ : អនុញ្ញាតអោយលោក **គីម ស្រ៊ី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២៧១១០១ ក.ណ ចុះថ្ងៃទី ០៧ - ៦ - ៨៩ អាស័យដ្ឋានបច្ចុប្បន្នភូមិ តាមេម ឃុំ ព្រែកស្តី ស្រុកកោះធំ ខេត្ត កណ្តាល បន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ២ : លោក **គីម ស្រ៊ី** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ភាគរយ ។

ប្រការ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៨៦

ប្រកាសលេខ :១២ ឧក. ប្រក

* * *

ប្រការ១ : អនុញ្ញាតអោយសិប្បកម្មកាត់ដេរសំលៀកបំពាក់ ដែលមានលោក **គង់ ជាវិទ្ធ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ៣៣០០១០ ភ.ព ចុះថ្ងៃទី ២៩ - ៤ - ៩២ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១២០ អឺ០ ផ្លូវស៊ីវត្ថា ក្រុមទី៣៦ សង្កាត់ បឹងកេងកងទី១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការផលិតកម្ម នៅក្នុង ទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៨៦

ប្រកាសលេខ :១៣ ឧក. ប្រក

* * *

ប្រការ១ : អនុញ្ញាតអោយលោក **លី គីមពាន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០០៥៤១៩ ក.ធ ចុះថ្ងៃទី ២២ - ១១ - ៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិកំពង់ក្របៅ ឃុំកំពង់ក្របៅ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ បើកដំណើរការសហគ្រាសផលិតគ្រឿង សង្ហារឹម នៅក្នុងទីតាំង ភូមិបល្ល័ង្កខាងលិច ឃុំដីរជាន់ខ្លា ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ។

ប្រការ២ : លោកលី **គឹម ពាទ** ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។

ប្រការ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់សហគ្រាសត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិស្ថាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ។

ប្រការ៤ : សហគ្រាសនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្តៈ គ្រែប្រអប់ តុទូ កៅអី សាឡុង ទ្វារ បង្អួច និងក្តារជឿគ្រប់ប្រភេទ ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺឈើដែលមានលក្ខណៈស្របច្បាប់ដែលសាមីសហគ្រាសត្រូវរ៉ាប់រង ដោះស្រាយដោយខ្លួនឯង ។

ប្រការ៥ : ម្ចាស់សហគ្រាសត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពផលិតកម្មរបស់សហគ្រាសផ្ញើមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែនិងថាមពល ខេត្តកំពង់ធំ ។

ប្រការ៦ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៨៦

ប្រកាសលេខ ១៤ ឧក. ប្រក

* * *

ប្រការ១ : អនុញ្ញាតអោយលោក **សុខ ហុខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២៩២៨៥៥ ភ.ព ចុះថ្ងៃទី ២៤ - ១០ - ៩០ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ៣ ឃុំដងទង ស្រុកស្មាច់មានជ័យ ខេត្ត កោះកុង បើកដំណើរការ រោងម៉ាស៊ីនផលិតទឹក កកដើម នៅក្នុងទីតាំងភូមិស្ទឹងវែង ឃុំស្ទឹងវែង ស្រុកស្មាច់មានជ័យ ខេត្ត កោះកុង ។

ប្រការ២ : លោក **សុខ ហុង** ត្រូវចាប់ផ្តើមរៀបចំរោងម៉ាស៊ីនផលិតទឹកកកដើម របស់ខ្លួនអោយស្រេច ជាស្ថាពរ ក្នុងរយៈពេល៦ខែ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសកាលកំណត់ ប្រកាសនេះត្រូវចាត់ទុកជាមោឃៈ ។

ប្រការ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ពូ សុធីរៈ

* * *

៣ - ឧស្សាហកម្ម រដ្ឋមន្ត្រីក្រសួងពតិមាន

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦

ប្រកាស លេខ ០១៥/៩៦ ពម.ប្រក

អនុញ្ញាតជូនលោក សិរី គិចសុវណ្ណ (SIRA KIJ SUWAN)

បើកក្រុមហ៊ុនផ្សព្វផ្សាយពាណិជ្ជកម្ម

* * *

រដ្ឋមន្ត្រី ក្រសួងពតិមាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ចុះថ្ងៃទី ០១ - ១១ - ៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងប្រកាស លេខ ១១៨ - ៩៥ ព.ម - ប្រក ចុះថ្ងៃទី ០៨ - ៦ - ១៩៩៥ របស់ក្រសួងពតិមាន

– យោងលិខិតសំណើសុំអនុញ្ញាតបើកក្រុមហ៊ុនផ្សព្វផ្សាយពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ - ០១ - ១៩៩៦

ប្រកាស

ប្រការ១ : អនុញ្ញាតជូនលោក **ស៊ីរី គិចសុវណ្ណ** " SIRI KIJSUWAN " សញ្ជាតិថៃ អោយបើកក្រុម ហ៊ុនផ្សព្វផ្សាយពាណិជ្ជកម្ម នៅព្រះរាជាណាចក្រកម្ពុជា PRAKIT / FCB (CAMBODIA) CO- , LTD ស្ថិតនៅផ្ទះលេខ ៣៣៧ ផ្លូវព្រះមុនីវង្ស សង្កាត់អូរ ឫស្សីទី៤ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

ប្រការ២: រាល់ដំណើរការផ្សព្វផ្សាយមិនត្រូវប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សង្គម និងត្រូវអោយ សមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៣ : លោក **ស៊ីរី គិចសុវណ្ណ** អ្នកគ្រប់គ្រងក្រុមហ៊ុនផ្សព្វផ្សាយពាណិជ្ជកម្ម នៅព្រះរាជាណាចក្រ កម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ , នាយកដ្ឋាន មណ្ឌលសារ ពត៌មាន ព្រមទាំងមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវអនុវត្តតាមប្រកាសនេះតាមភារកិច្ច រៀងៗខ្លួន ។

ប្រការ៤ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

៤ - ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៤៣ អយក .ប្រក

ស្តីពីការប្តូរឈ្មោះ អនុវិទ្យាល័យ ចរិយាវង្ស ទៅជាអនុវិទ្យាល័យ

ព្រះ នរោត្តម រណឫទ្ធិ ស្ថិតនៅក្នុងស្រុកកំពត ខេត្តកំពត

* * *

រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ -១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ។
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- យោងលិខិតរបស់សាលាខេត្ត កំពត លេខ ១៣៤ ក.ព.៩៥ ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៩៥
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

ប្រកាស

ប្រការ១ : អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យ ចរិយាវង្ស បច្ចុប្បន្នទៅជា « **អនុវិទ្យាល័យ ព្រះ នរោត្តមរណឫទ្ធិ** » ចាប់ពីឆ្នាំសិក្សា ១៩៩៥ - ៩៦ តទៅ ។

ប្រការ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបាត់តាំង និងប្រធាននាយកដ្ឋានផែនការនិងហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡាមានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

ហត្ថលេខានិងត្រា

តុល ឡោះ

* * *

៥ - ទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

ភ្នំពេញ,ថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៦

ប្រកាស លេខ ០០៣ បទ.ប្រក

អនុញ្ញាតអោយអង្គការមនុស្សលោកថ្មី ប្រើប្រាស់វិទ្យុទាក់ទងប្រភេទ VHF ចំនួន ៥ គ្រឿង

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ - ១១ - ៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ - ៣- ៨៧ ស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញពាក្យស្នើសុំបន្តការប្រើប្រាស់វិទ្យុប្រភេទ VHF របស់អង្គការមនុស្សលោកថ្មី លេខ ០០២២១០៤ ចុះថ្ងៃទី ១៥ /១២ /៩៥
- ប្រកាសលេខ ១៣០ បទ ប្រកទអ ចុះថ្ងៃទី ២៧/៩/៩៤
- ប្រកាសលេខ ១៥៩ បទ ប្រកទអ ចុះថ្ងៃទី ១៣/១០/៩៤
- សេចក្តីជូនដំណឹងលេខ ២៧៤៩ បទ ចុះថ្ងៃទី ០៥/១០/៩៥

ប្រកាស

ប្រការ១ : អនុញ្ញាតអោយអង្គការមនុស្សលោកថ្មីបន្តការប្រើប្រាស់វិទ្យុទាក់ទងប្រភេទ VHF ចំនួន ០៥ គ្រឿង ។

ប្រការ២ : ប្រកាសលេខ ១៣០ បទ ប្រកទអ ចុះថ្ងៃទី ២៧/០៩/៩៤ និងប្រកាសលេខ ១៧៩ បទប្រកទអ ចុះថ្ងៃទី ១៣/១០/៩៤ ទុកជានិរាករណ៍ ។

ប្រការ៣ : នាយកខុទ្ទកាល័យ ប្រធានអធិការកិច្ច នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋានផែនការ គណនេយ្យនិងហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនា គមន៍អន្តរជាតិនិងអង្គការមនុស្សលោកថ្មី ត្រូវអនុវត្តតាមប្រកាសនេះ ។

ប្រការ៤ : ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

សុ ឃុន

* * *

៦ - ឯកសារក្រសួងធម្មការ និង សាសនា

ប្រកាស

ភ្នំពេញ,ថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៦

ប្រកាស លេខ ០៦/៩៦ ក.ធ.ស

ស្តីពីការលុបសេចក្តីសំរេចលេខ ២១៧/៩៥ កធស

ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម **សីហនុវរ្ម័ន** ព្រះចៅនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងនាយករដ្ឋមន្ត្រីទី១ និង ទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ។

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុវរ្ម័ន** ព្រះចៅនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញលិខិតស្នើសុំធ្វើច្បាប់ថ្មីរបស់ព្រះវិហារ « ខុងម៉ឹងសុិនតាវអៀន ចិនតៃរ៉ាន់ » ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩៥ ។

ប្រកាស

ប្រការ១ : លុបសេចក្តីសំរេច លេខ ២១៧ / ៩៥ កធស ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥ «ស្តីពីការអនុញ្ញាតអោយបង្កើតសាខា ព្រះវិហារសាសនា ខុងម៉ឹងធានតាវអៀន » ។

ប្រការ២ : នាយកដ្ឋានសាសនា និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍ សេចក្តីប្រកាសនេះអោយមានប្រសិទ្ធភាព ។

ប្រការ៣ : សេចក្តីប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខានិងត្រា

ហៀង វណ្ណារិទ្ធ

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៦០០ រៀល